ឧក្រិដ្ឋកម្មធ្វើឱ្យអ្នករាល់គ្នាឈឺចាប់
យើងអាចជួយបាន

CalVCP

កម្មវិធីផ្តល់សំណងសម្រាប់ជនរងគ្រោះនៅរដ្ឋកាលីហ្វ័រញ៉ា

មាតិកា

សូមណែនាំមកកាន់ CalVCP	2
ទទួលជំនួយក្នុងស្រុក	2
អ្នកដែលមានសិទ្ធិទទួល	3
សាក្សីជាកុមារ	4
របៀបធ្វើឱ្យមានសិទ្ធិទទួល	4
ការចំណាយដែលគ្របដណ្តប់	6
ការបង់ប្រាក់ពេលមានអាសន្ន	6
ការប្តូរទីតាំង	6
ដំណើរការនៃពាក្យសុំ	7
សិទ្ធិក្នុងការទទួលសំណង	9
សិទ្ធិក្នុងការដាក់បណ្តឹងសារទុក	10

ទាក់ទង CalVCP

សម្រាប់ព័ត៌មានបន្ថែម
សូមទូរស័ព្ទមក 800.777.9229
ឬចូលមើល calvcp.ca.gov

CalVCP

តើអ្វីជាកម្មវិធីសំណងសម្រាប់ជនរងគ្រោះ?

កម្មវិធីផ្តល់សំណងសម្រាប់ជនរងគ្រោះនៅរដ្ឋកាលីហ្វ័រញ៉ា (CalVCP) ដែលបានបង្កើតឡើងនៅឆ្នាំ 1965 គឺជាកម្មវិធីរដ្ឋដែលប្តេជ្ញាផ្តល់សំណងសម្រាប់ការចំណាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដល់ជនរងគ្រោះដែលមានសិទ្ធិទទួលដែលទទួលរងរបួសផ្នែករាងកាយ ឬរងគ្រោះពីការគំរាមកំហែងពីការបួសផ្នែករាងកាយ ដែលជាលទ្ធផលផ្ទាល់នៃឧក្រិដ្ឋកម្មដ៏ហិង្សា។

តើខ្ញុំទទួលជំនួយក្នុងស្រុកដោយរបៀបណា?

មជ្ឈមណ្ឌលជំនួយសាក្សីសម្រាប់ជនរងគ្រោះ (Victim Witness Assistance Center) ផ្តល់ជំបូន្ថានផ្នែកច្បាប់នៅទូទាំងរដ្ឋ និងធ្វើការដោយផ្ទាល់ជាមួយ CalVCP ដើម្បីជួយជនរងគ្រោះក្នុងការដាក់ពាក្យសុំសំណង និងតម្រង់ទិសទៅប្រព័ន្ធយុត្តិធម៌នៃឧក្រិដ្ឋកម្ម។

សូមទាក់ទងដើម្បីទទួលបានជំបូន្ថានផ្នែកច្បាប់ និងធនធានសម្រាប់ជនរងគ្រោះបន្ថែមទៀតនៅក្នុងប្រទេសរបស់អ្នក តាមរយៈចូលមើលទំព័រជំនួយប្រចាំតំបន់របស់យើង៖
calvcp.ca.gov/localhelp.aspx

តើអ្វីជាកម្មវិធីសំណងសម្រាប់ជនរងគ្រោះ?

CalVCP អាចជួយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចតទៅ៖

- ការរុកគួន
- ការបំពានលើកុមារ
- អំពើហិង្សាក្នុងគ្រួសារ
- ការបើកបរដោយស្រវឹង
- ការបំពានលើមនុស្សចាស់
- ឧក្រិដ្ឋកម្មដោយការស្អប់ខ្ពើម
- ឃាតកម្ម
- ការជួញដូរមនុស្ស
- ការប្លន់
- ការរំលោភបំពានតាមបណ្តាញអ៊ីនធឺណិត
- ការបំពានផ្លូវភេទ
- ការតាមឈ្លប
- អំពើមនុស្សឃាត (ពាក់ព័ន្ធនឹងរថយន្ត)

CalVCP អាចជួយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលកើតឡើងនៅរដ្ឋកាលីហ្វ័រញ៉ា និងអ្នករស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាដែលក្លាយជាជនរងគ្រោះ នៅពេលដែលពួកគេកំពុងទៅលេងរដ្ឋ ឬប្រទេសផ្សេង។

CalVCP អាចនឹងជួយអ្នកផ្សេងទៀត ដែលរងការប៉ះពាល់ដោយឧក្រិដ្ឋកម្ម រួមមាន៖

- ប្តី/ប្រពន្ធ ឬដៃគូក្នុងគ្រួសារ
- កូន
- ឪពុកម្តាយ
- អាណាព្យាបាលស្របច្បាប់
- អ្នកដែលចាត់ទុកជាអ្នកទទួលខុសត្រូវស្របច្បាប់ ឬខាងហិរញ្ញវត្ថុសម្រាប់ការចំណាយរបស់ជនរងគ្រោះដែលបានបាត់បង់ជីវិត
- សាក្សីជាកុមារ
- បងប្អូនប្រុសស្រី
- ជីដូនជីតា
- ចៅ
- អ្នកដែលរស់នៅក្នុងផ្ទះតែមួយ ជាមួយនឹងជនរងគ្រោះក្នុងរយៈពេលមិនតិចជាងពីរឆ្នាំ ឬនៅពេលមានឧក្រិដ្ឋកម្មកើតឡើង។

តើយ៉ាងដូម្តេចវិញ ប្រសិនបើកុមារបានឃើញឧក្រិដ្ឋកម្មហិង្សា?

កុមារអាយុក្រោម 18 ដែលរងគ្រោះដោយការបួសខាងអារម្មណ៍ដោយសារបានឃើញឧក្រិដ្ឋកម្មហិង្សា អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានអត្ថប្រយោជន៍ខាងប្រឹក្សាសុខភាពឥណ្ឌល បើទោះបីជាពួកគេមិនពាក់ព័ន្ធនឹងជនរងគ្រោះដោយឧក្រិដ្ឋកម្មក៏ដោយ។ សាក្សីជាអនីតិជនត្រូវតែស្ថិតក្នុងភាពជិតស្និតនឹងឧក្រិដ្ឋកម្ម។

តើខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលសំណងសម្រាប់ជនរងគ្រោះដោយរបៀបណា?

- រាយការណ៍អំពីឧក្រិដ្ឋកម្មទៅប៉ូលីស នគរបាល សេវាកម្មការពារកុមារ ឬទីភ្នាក់ងារអនុវត្តិច្បាប់ផ្សេងទៀត។
- ដាក់ពាក្យទៅកាន់ CalVCP ក្នុងរយៈពេលបីឆ្នាំបន្ទាប់ពីថ្ងៃកើតបទឧក្រិដ្ឋ(សម្រាប់ពាក្យស្នើសុំដែល ទទួលបាននៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2013)។
- ជនរងគ្រោះជាអនីតិជន (ក្រោម 18 ឆ្នាំ) អាចដាក់ពាក្យរហូតដល់ថ្ងៃខួបកំណើតលើកទី 21 របស់ខ្លួន។ សម្រាប់អនីតិជន ដែលជាជនរងគ្រោះនៃការរំលោភផ្លូវភេទ អាចដាក់បណ្តឹងនៅពេលណាមួយក៏បានរហូតដល់ថ្ងៃខួបកំណើតលើកទី 28 របស់ខ្លួន។
- សហការជាមួយការអនុវត្តច្បាប់ដោយសមហេតុផល នៅពេលស៊ើបអង្កេត និងការកាត់សេចក្តីលើបទឧក្រិដ្ឋ។
- សហការជាមួយ CalVCP តាមរយៈការផ្តល់ព័ត៌មានដែលត្រូវការដើម្បីត្រួតពិនិត្យវាយតម្លៃពាក្យសុំ និងការចំណាយ។
- មិនអាចពាក់ព័ន្ធនៅក្នុងហេតុការណ៍ដែលឈានដល់ការកើតមានបទឧក្រិដ្ឋ។

តើការចំណាយអ្វីដែល CALVCP អាចជួយបង់អោយ?

CalVCP អាចជួយទូទាត់ថ្លៃចំណាយផ្សេងៗដែលទាក់ទងទៅនឹងបទឧក្រិដ្ឋដូចជា:

- ការព្យាបាលខាងថ្នាំពេទ្យ និងខាងមាត់ធ្មេញ
- សេវាសុខភាពផ្លូវក្បាល
- ការបាត់បង់ប្រាក់ចំណូល
- ការចំណាយលើបុណ្យសព និងការកប់
- ការបាត់បង់ការគាំពារដល់អ្នកក្តាងបន្តក នៅពេលជនរងគ្រោះស្លាប់បាត់បង់ជីវិត ឬមានពិការភាពជាអចិន្ត្រៃយ៍
- សន្តិសុខនៃការរស់នៅ
- ការប្តូរទីតាំង
- ការសម្អាត់កន្លែងកើតហេតុ
- ការកែកុនគេហដ្ឋាន ឬយានយន្តសម្រាប់ជនរងគ្រោះ ដែលធ្លាក់ខ្លួនពិការ
- សម្ភារៈផ្នែកព្យាបាល

មានការកំណត់លើចំនួនដែលអាចបង់សម្រាប់ការបាត់បង់នីមួយៗ។

តើការចំណាយអ្វីដែល CALVCP មិនអាចបង់អោយ?

- ការចំណាយណាដែលមិនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម
- ការចំណាយណាដែលបានបង់ដោយជនាវ៉ាប់រង ឬប្រភពសំណង ឬការគ្របដណ្តប់ផ្សេងទៀត
- ការចំណាយសម្រាប់ទ្រព្យសម្បត្តិដែលបានបាត់បង់ លួច ឬខូចខាត
- ការខូចខាតសម្រាប់ការឈឺចាប់ ឬការរងគ្រោះ

CalVCP មិនអាចបង់ថ្លៃសម្រាប់ការចំណាយដែលបានកើតឡើងខណៈដែលបុគ្គលម្នាក់នេះស្ថិតនៅក្រោមការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន, ការព្យួរទោស ឬការត្រួតពិនិត្យដោយសហគមន៍ចំពោះការដោះលែងនៅពេលក្រោយសម្រាប់បទឧក្រិដ្ឋហិង្សា, ដាក់ពន្ធនាគារ ឬតម្រូវតាមច្បាប់ដើម្បីចុះឈ្មោះថាជាជនល្មើសផ្នែកផ្លូវ ភេទ។

តើយ៉ាងដូម្តេចវិញ ប្រសិនបើខ្ញុំត្រូវការជំនួយផ្នែកហិរញ្ញវត្ថុភ្លាមៗ?

តាមស្ថានភាពជាក់លាក់ CalVCP អាចផ្តល់ដល់បេក្ខជនន៍នូវជំនួយហិរញ្ញវត្ថុពេលមានអាសន្ន ក្នុងរយៈពេល 30 ថ្ងៃ។ ឧទាហរណ៍: អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានជំនួយពេលមានអាសន្ន ប្រសិនបើសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកស្ថិតក្នុងហានិភ័យ ហើយអ្នកត្រូវតែប្តូរទីតាំង។ ឯកសារចាំបាច់ត្រូវតែផ្តល់ឱ្យបានទាន់ពេល។

តើ CALVCP នឹងបង់ការចំណាយលើការប្តូរទីតាំងរបស់ខ្ញុំឬទេ?

CalVCP អាចជួយបង់ការចំណាយនានា ដូចជាការជួល ការកក់ និង បង់ប្រាក់ជួលបណ្តោះអាសន្នសម្រាប់ខែដំបូង និងខែចុងក្រោយរបស់ជនរងគ្រោះ ដើម្បីប្តូរទីតាំងក្នុងគោលដៅសុវត្ថិភាព ឬភាពសុខស្រួលផ្នែកអារម្មណ៍។

ទម្រង់បែបបទប្តូរទីតាំងអាចមានតាម **calvcp.ca.gov** ។ ដំបូន្មានផ្នែកច្បាប់ដល់ជនរងគ្រោះក្នុងស្រុកអាចជួយដល់ដំណើរការនេះ។

តើយ៉ាងដូម្តេចវិញ ប្រសិនបើសម្ភារៈព្យាបាលត្រូវបានបាត់បង់ ចោរលួច ឬបំផ្លាញ?

CalVCP អាចបង់លើរបស់របរចាំបាច់ខាងព្យាបាល ដូចជា កៅអីរុញ ឈើច្រត់ វែនតា និងធ្មេញដាក់ទាំងស្និត ដែលត្រូវបានបាត់បង់ ចោរលួច ឬខូចខាតនៅពេលមានឧក្រិដ្ឋកម្ម ឬក្លាយជាចាំបាច់ ដោយសារតែឧក្រិដ្ឋកម្ម។

តើយ៉ាងដូចម្តេចដែរ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រង ឬប្រភពផ្សេងទៀតបង់ថ្លៃចំណាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម?

CalVCP គឺជាអ្នកបង់ប្រាក់ឱ្យនៅពេលចុងក្រោយបំផុត និងអាចផ្តល់សំណងដល់ជនរងគ្រោះសម្រាប់ការចំណាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម តែក្នុងរណីដែលមិនមានប្រភពសំណងផ្សេងទៀតប៉ុណ្ណោះ។ ប្រសិនបើ CalVCP ផ្តល់សំណងដល់ជនរងគ្រោះសម្រាប់ការបាត់បង់ប៉ុន្តែស្រាប់តែមានប្រភពនៃការផ្តល់មូនិធិផ្សេងទៀតសម្រាប់ជនរងគ្រោះ ដោយសារតែឧបទ្ទវហេតុមានលក្ខណៈសម្បត្តិតែមួយ នោះ CalVCP ត្រូវយកសំណងវិញ។

CalVCP ធ្វើការជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងដើម្បីកំណត់ថ្លៃវិក្កប័ត្រប៉ុន្មាន ដែលមានលក្ខណៈសម្បត្តិត្រប់គ្រាន់សម្រាប់ការបង់ប្រាក់។ មានតែក្រុមហ៊ុនធានារ៉ាប់រងការចំណាយឬប្រភពផ្សេងទៀតដែលមិនបង់ប៉ុណ្ណោះ ដែលអាចត្រូវបានគិតគូសម្រាប់ការបង់ ដែលអាចរួមមានការចូលរួមចំណែកបង់ថ្លៃព្យាបាលពេលទៅពេទ្យម្តងៗ ថ្លៃកាត់ចេញ និងការចែករំលែកនៃការបង់ប្រាក់ថ្លៃដើម។

តើ CALVCP បង់ថ្លៃវិក្កយបត្ររបស់ខ្ញុំ ឬការចំណាយដោយរបៀបណា?

CalVCP គឺជាអ្នកបង់ប្រាក់ឱ្យនហៅពលេចុងក្រោយបំផុត និងត្រូវតពើនិតុយបញ្ជាក់គ្រប់ប្រភពសំណងផ្សងៗទាំងអស់។

CalVCP នឹងឆ្លលើយតបទហៅអ្នកផ្តល់សវោ ដហើម្បីពិនិតុយបញ្ជាក់ថា វិក្កយបត្រទាំងអស់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដាក់អនុវត្តតម្រលនៃការបង់ និងនហៅក្នុងករណីភាគច្រហើនបំផុត បង់ឱ្យអ្នកផ្តល់សវោដហោយផ្ទាល់សម្រាប់ការចំណាយពាក់ព័ន្ធនឹងការព្យបាល និងសុខភាពខួលក្បាល។

ប្រសិនបហើជនរងគ្រោះខកខានការងារ ដហោយសារតកោររងរបួសពីឧក្រិដ្ឋកម្ម និងកំពុងពាក្យសុំទាក់ទងនឹងការបាត់បង់ប្រាក់ឈ្នួល CalVCP នឹងត្រូវការព័ត៌មានពីនិយហោជិត និងសចេក្តីថ្លៃដែការណ៍អំពីពិការភាពពីអ្នកផ្តល់សវោថទៅងសុខភាព។ ប្រសិនបហើជនរងគ្រោះគឺជាអ្នកដលែមានការងារផ្ទាល់ខ្លួន CalVCP ត្រូវការទម្រង់រាយការណ៍អំពីការរកប្រាក់បានក្នុងរយៈពលេពីរឆ្នាំ។

ប្រសិនបហើជនរងគ្រោះបានបង់លហើការចំណាយមុនការដាក់ពាក្យសុំជាមួយ CalVCP ពួកគនើងត្រូវទទួលសំណងដហោយផ្ទាល់។

ប្រសិនបហើ CalVCP បង់ឱ្យអ្នកផ្តល់ ហហើយអ្នកផ្តល់សវោយកសាច់ប្រាក់ចញ្ចពីសកែ អ្នកផ្តល់សវោមិនអាចស្នហើជនរងគ្រោះបង់ប្រាក់បន្ថមែតាមវិក្កយបត្រនហោះទ។ ប្រសិនបហើជនរងគ្រោះត្រូវស្នហើឱ្យបង់ប្រាក់ថ្លលវិក្កយបត្រដលែកម្មមវិធីបានបង់ ការផ្តល់ដំបូន្មានផ្នកែចុបាប់ដល់ជនរងគ្លរតដើងឬជនរងគ្រោះគ្លរតទ្វែរស័ព្ទមក CalVCP តាមលខេ 800.777.9229។

តើខ្ញុំបង់សំណងដល់ជនរងគ្រោះដោយរបៀបណា?

- ទាក់ទងមជ្ឈមណ្ឌលជំនួយសាក្សីជនរងគ្រោះក្នុងស្រុកតាម **calvcp.ca.gov/localhelp.aspx** ។ ការផ្តល់ដំបូន្មានផ្នែកច្បាប់ដល់ជនរងគ្រោះអាចជួយជនរងគ្រោះបានយ៉ាងពេញលេញ និងជួយដាក់ពាក្យជូន ព្រមទាំងជួយជនរងគ្រោះស្វែងយល់បន្ថែមអំពីប្រព័ន្ធយុត្តិធម៌នៃឧក្រិដ្ឋកម្មទៀតផង។
- ទូរស័ព្ទទៅ CalVCP at **800.777.9229**
- ដោនឡតពាក្យសុំតាម **calvcp.ca.gov**
- ផ្ញើអ៊ីម៉ែលទៅ CalVCP តាម **info@vcgcb.ca.gov**

តើមានតម្រូវការអ្វីទៀតដែលត្រូវដាក់ជាមួយនឹងពាក្យសុំរបស់ខ្ញុំ?

នៅពេលអាចរកបាន ត្រូវដាក់ច្បាប់ចម្លងនៃ៖

- ប័ណ្ណជានារ៉ាប់រងខាងការព្យាបាល
- កំណត់ត្រាខាងការព្យាបាលដែលចងក្រងជាឯកសារនូវការរងរបួសដោយឧក្រិដ្ឋកម្ម ប្រសិនបើអាចអនុវត្តបាន
- វិក្កយបត្រថ្លៃផ្នែកព្យាបាល ផ្នែកមាត់ធ្មេញ ឬផ្នែកផ្លូវចិត្ត ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម
- បង្កាន់ដៃណាមួយដែលពិនិត្យបញ្ជាក់ការបង់ប្រាក់ថ្លៃវិក្កយបត្រដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ឬការចំណាយនានា
- របាយការណ៍ឧក្រិដ្ឋកម្មពេញលេញ ប្រសិនបើអាចរកបាន

ដាក់វិក្កយបត្រ និងសំណួរនានាទៅ៖
CalVCP
P.O. Box 3036
Sacramento, CA 95812-3036

តើខ្ញុំទទួលសំណងដែលចេញបញ្ហាដោយតុលាការ និងជំនួយរបស់ CALVCP បានឬទេ?

ចាស/បាទ តុលាការអាចបញ្ហាឱ្យមានការសងពីអ្នកប៉ះពាល់ក្នុងនាមជនរងគ្រោះទាំងអស់ ដែលរងគ្រោះពីការបាត់បង់ផ្ទៃកហិរញ្ញវត្ថុ ដោយសារតែឧក្រិដ្ឋកម្ម។ជនរងគ្រោះនឹងត្រូវធ្វើការជាមួយអ្នកផ្តល់ជំបូន្ថានផ្ទៃកច្បាប់សម្រាប់ជនរងគ្រោះ អនុស្ថាក្តីប្រចាំសង្កាត់ និង/ឬការិយាល័យឃ្លាំមើលកុំឱ្យប្រព្រឹត្តិបទឧក្រិដ្ឋផ្សេងទៀត ប្រចាំប្រទេស ដើម្បីដាក់ការចំណាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដូច្នេះតុលាការអាចបញ្ហាឱ្យមានការផ្តល់សំណង។

សំណងមានពីរប្រភេទ៖ ការបញ្ហា និងការពិន័យ។ ការពិន័យគឺជាចំនួន ដែលបានកំណត់ដោយប្រភេទនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិ ដែលអ្នកប៉ះពាលត្រូវបង់ត្លងនាមជាប់ណុលទៅសង្គម។ ឧក្រិដ្ឋកម្មរួមមាន ឃាតកម្ម ការចោទប្រកាន់ពាក់ព័ន្ធនឹងគ្រឿងញៀន ការរុកគួនផ្ទៃកផ្លូវភេទ និងការចាប់ជំរិត គឺសុទ្ធតែស្ថិតក្រោមការពិន័យសំណងសម្រាប់ឧក្រិតដ្ឋកម្មធ្ងន់ធរ គឺពី $200 ទៅ $10,000។ ការពិន័យគឺត្រូវដាក់ដោយផ្ទាល់ទៅមូនិធិសំណងរបស់រដ្ឋ ដើម្បីផ្តល់សម្រាប់សំណងជនរងគ្រោះ។

ការបញ្ហាគឺជាចំនួនដែលកំណត់ដោយតុលាការ ដែលមានជំនួយពីជនរងគ្រោះ និងរាជអាជ្ញា ដែលត្រូវបង់ដោយផ្ទាល់ទៅជនរងគ្រោះ ឬក្រួសារសម្រាប់ផ្លែពិតប្រាកដនៃឧក្រិដ្ឋកម្ម។ ប្រសិនបើអ្នកប៉ះពាលត្រូវបានចោទប្រកាន់ថាមានកំហុស តុលាការត្រូវតែចេញបញ្ហាសំណង ដែលតម្រូវឱ្យពួកគេបង់ដល់ជនរងគ្រោះនូវការបាត់បង់ផ្ទៃកហិរញ្ញវត្ថុដែលបណ្តាលមកពីឧក្រិដ្ឋកម្ម។

ជារឿយៗ ជនរងគ្រោះមានការចំណាយដោយសារឧក្រិដ្ឋកម្មដែលត្រូវការការបង់ប្រាក់មុននឹងអាចរកបានសំណងពីអ្នកប៉ះពាល។ CalVCP អាចផ្តល់ជំនួយជាហិរញ្ញវត្ថុសម្រាប់ការចំណាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រហូតដល់ទទួលបានសំណងដែលជាចំណុចដែល CalVCP ត្រូវតែសង។

តើខ្ញុំមានសិទ្ធដាក់បណ្តឹងសារទុកឬទេ?

ចាស/ចាទ ប្រសិនបើអ្នកមិនយល់ព្រមជាមួយនឹងអនុសាសន៍ក្នុងការបដិសេធន៍លក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬការចំណាយ អ្នកអាចដាក់បណ្តឹងសាទុកក្នុងរយៈពេល 45 ថ្ងៃ។ អ្នកមិនត្រូវការស្នាក្តីដើម្បីដាក់បណ្តឹងសារទុកទេ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័ររបស់យើងតាម **calvcp.ca.gov** ឬទូរស័ព្ទមកលេខ **800.777.9229**។

ភាពសម្ងាត់នៃការទាមទារ

ការទាមទារទាំងអស់ដែលបានដាក់ជាមួយនឹង CalVCP ត្រូវបានរក្សាការសម្ងាត់លើកលែងតែត្រូវដោយច្បាប់។ CalVCP បង្ហាញតែព័ត៌មានរបស់ជនរងគ្រោះណាដែលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ។ ប្រសិនបើជនរងគ្រោះគឺជាកុមារ ឬមនុស្សពេញវ័យដែលមិនអាចធ្វើអ្វីៗបានជាប្រក្រតី ការអនុញ្ញាតជាលាយលក្ខណ៍អក្សរត្រូវតែផ្តល់ដោយមាតាបិតា អាណាព្យាបាល ឬអ្នកផ្សេងទៀតដែលទទួលការអនុញ្ញាតស្របច្បាប់ ដើម្បីតំណាងឱ្យជនរងគ្រោះ។

CalVCP

កម្មវិធីផ្តល់សំណងសម្រាប់ជនរងគ្រោះនៅរដ្ឋកាលីហ្វ័រញ៉ា

P.O. Box 3036
Sacramento, CA 95812-3036

800.777.9229
info@vcgcb.ca.gov
calvcp.ca.gov

ភាសាទាំងអស់ដែលមាន។ ការថ្លង់ និងការពិបាកស្តាប់៖ សូមហៅទូរស័ព្ទមកសេវាកម្មសេវាកម្មប្រាប់បន្តរបស់រដ្ឋកាលីហ្វ័រញ៉ា (California Relay Services) តាមលេខ 711។

rev. 4.12.2016

ឯកសារនេះត្រូវបានផលិតឡើងដោយ CalVCP ក្រោមលេខ 2014-VF-GX-K012, ដែលផ្តល់ដោយការិយាល័យសម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋ ការិយាល័យនៃកម្មវិធីយុត្តិធម៌ ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ មតិយោបល់ លទ្ធផលរកឃើញ និងសេចក្តីសន្និដ្ឋានដែលបានបង្ហាញនៅក្នុងឯកសារនេះគឺជាកម្មសិទ្ធិ របស់អ្នកចូលរួមចំណែក និងមិនបង្ហាញពីគោលនយោបាយផ្លូវការរបស់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក